ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៥...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំព្រេច ខេត្តមណ្ឌលគិរី

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការស្នើសុំរបស់ក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ដែលមានផ្ទៃដីសរុបទំហំ ២២២.៥០០ (ពីរសែនពីរម៉ឺនពីរពាន់ប្រាំរយ) ហិកតា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងនិយាមកា (Datum: WGS1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដើម្បីៈ

- ធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំព្រេច
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រខេត្តមណ្ឌលគិរី ជា ៤ តំបន់ ដែលរួមមានៈ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ សម្រាប់បម្រើដល់ការងារគ្រប់គ្រង ថែរក្សា អភិរក្ស និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តភាព។

១. **តំបន់ស្នូល** មានចំនួន ០២កន្លែង មានផ្ទៃដីសរុប ៤៥.៤៨០ (បួនម៉ឺនប្រាំពាន់បួនរយប៉ែតសិប) ហិកតា តំបន់ស្នូលទី១ (CRZ1) ស្ថិតនៅតំបន់ក្រង់ជន្លក ព្រៃក្រង់ណាត និងព្រៃក្រង់រពុក និងតំបន់ស្នូលទី២ (CRZ2) ភាគច្រើនជាតំបន់ព្រៃពាក់កណ្តាលស្រោងនៃតំបន់ភ្នំគុណាស្យាល់ ស្ថិតនៅភាគពាយ័ព្យ នៃដែលជម្រកសត្វព្រៃភ្នំព្រេច ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

២. **តំបន់អភិរក្ស** មានចំនួន ០១កន្លែង មានផ្ទៃដីសរុប ៧៨.៨៥០ (ប្រាំពីរម៉ឺនប្រាំបីពាន់ប្រាំបីរយហាសិប) ហិកតា តំបន់នេះភាគច្រើនៅព័ទ្ធជុំវិញតំបន់ស្នូល និងមួយផ្នែកទៀតស្ថិតនៅភាគនិរតីនៃដែនជម្រកសត្វព្រៃភ្នំព្រេច ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

៣. **តំបន់ប្រើប្រាស់ដោយចីរភាព** មានចំនួន ០៥កន្លែង មានផ្ទៃដីសរុប ៩១.៣៩៥ (ប្រាំបួនម៉ឺនមួយពាន់បីរយកៅសិបប្រាំ) ហិកតា ដែលរួមមានៈ តំបន់ (SUZ1) ស្ថិតនៅឃុំស្រែកឈូក និងឃុំប៊ូស្រ្ទី (SUZ2) ស្ថិតនៅឃុំចុងប្លាស់និងឃុំប៊ូស្រ្ទីនៃតំបន់អូររយោល តំបន់ (SUZ3) ស្ថិតនៅឃុំចុងប្លាស់នៃតំបន់ភ្នំរហាវ តំបន់ (SUZ4) ស្ថិតនៅឃុំចុងប្លាស់ ឃុំពូជ្រៃ និងឃុំសុខសាន្តនៃតំបន់ព្រែកឈូង និងតំបន់ (SUZ5) ស្ថិតនៅឃុំប៊ូស្រ្ទី។

៤. **តំបន់សហគមន៍** មានចំនួន ០៧កន្លែង មានផ្ទៃដីសរុប ៦.៧៧៥ (ប្រាំមួយពាន់ប្រាំពីររយចិតសិបប្រាំ) ហិកតា ដែលរួមមានៈ តំបន់សហគមន៍ទី១ (CMZ1) ស្ថិតនៅភូមិស្រែអ៊ី សង្កាត់រមនា តំបន់ទី២ (CMZ2) ស្ថិតនៅភូមិមេម៉ងនិងភូមិពូកេះ ឃុំមេម៉ង់ ភូមិពូទុង ភូមិពូងោល ភូមិញ៉ៅ ភូមិពូហ៊ួន និងភូមិខ្ទូល ឃុំចុងផ្លាស់ ភូមិខ្វែង ឃុំប៊ូស្រ្ទី ភូមិពូចា និងភូមិទី១ ឃុំស្រែឈូក តំបន់ទី៣ (CMZ3) ស្ថិតនៅជាប់អូរទេនៃឃុំចុងផ្លាស់ តំបន់ទី៤ (CMZ4) ស្ថិតនៅភូមិព្រះ ឃុំចុងផ្លាស់ តំបន់ទី៥

(CMZ5) ស្ថិតនៅជាប់អូរឈូងនៃឃុំចុងផ្លាស់ តំបន់ទី៦ (CMZ6) ស្ថិតនៅតាមព្រែកឈូងនៃឃុំប៊ូស្រា និងតំបន់ទី៧ (CMZ7) ស្ថិតនៅឃុំសុខសាន្ត ដែលមាននិយាមកាក្នុងឧបសម្ព័ន្ធ២។

**មាត្រា៤ .-**

តំបន់គ្រប់គ្រងនីមួយៗក្នុងដែនជម្រកសត្វព្រៃភ្នំព្រេចនេះ អាចត្រូវបានធ្វើការកែប្រែក្នុងករណីចាំបាច់ដោយយោងតាមការសិក្សាស្រាវជ្រាវលើធនធានធម្មជាតិ និងតាមតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៧

**ជ.នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ